MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

# សហគមន៍មានសុវត្ថិភាព ១

adpc

មិថុនា២០០៩

# ការបង្កើនសមត្ថភាព គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត ស្រុក និង ឃុំ នៅប្រទេសកម្ពុជា

## ការរៀបចំ និង ការអនុវត្តន៍កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់

### ពត៌មានសង្ខេប

ករណីសិក្សានេះផ្តោតលើការរៀបចំ និងការអនុវត្តន៍កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ នៅក្នុងខេត្តចំនួន ២ ក្នុងប្រទេសកម្ពុជា។ វាបង្ហាញពីការដកស្រង់ពីគំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ជាកម្មវិធីរបស់គណៈកម្មការទន្លេមេគង្គ និងបង្ហាញពីវិធីសាស្ត្រក្នុងការការពារជីវិត និងការទាញយកផលប្រយោជន៍វិជ្ជមានពីទឹកជំនន់។ ករណីសិក្សានេះក៏បានបង្ហាញផងដែរ ពីកង្វះខាត និងតំរូវការសំរាប់ពង្រឹងប្រព័ន្ធគ្រប់គ្រងគ្រោះទឹកជំនន់ដែលមានស្រាប់ និង បង្ហាញពីរបៀបក្នុងការរៀបចំកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់។ កម្មវិធីនេះមានគោលបំណងបំពេញនូវកង្វះខាតដោយការពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត និង ស្រុក ។

### ខ្លឹមសាររឿង

■ វិធីសាស្ត្រនៃការគ្រប់គ្រងគ្រោះទឹកជំនន់ ថ្នាក់តំបន់ ២
■ កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ ៣
■ មេរៀនបទពិសោធន៍/ឧបសគ្គពេលអនាគត ៦




*ទឹកជំនន់ជាព្រឹត្តិការណ៍មួយដែលកើតមានឡើងប្រចាំឆ្នាំក្នុងប្រទេសកម្ពុជា ។ដោយសារទឹកជំនន់នេះ ពលរដ្ឋនៅតាមមូលដ្ឋានក៏អាចទទួលបានផលប្រយោជន៍ពីហេតុការណ៍ធម្មជាតិនេះ និងភាគច្រើនក៏ទទួលរងទុក្ខវេទនា ដោយមានការបាត់បង់ជីវិត ខូចខាតហេដ្ឋារចនាសម្ព័ន្ធ និងប៉ះពាល់ជីវភាពរស់នៅផងដែរ ។ ដូច្នេះហើយ ទើបប្រពន្ធ័ឆ្លើយតបគ្រោះទឹកជំនន់ ដែលបានយកចិត្តទុកដាក់សំខាន់លើការត្រៀមបង្ការដ៏សមស្រប ដើម្បីកាត់បន្ថយការខូចខាតទាំងនេះ តាមរយៈការពង្រឹងសមត្ថភាព និងការផ្តល់ជំនួយបច្ចេកទេស ។*

## សេចក្តីផ្តើម

ទន្លេមេគង្គ ជាដង្ហើមសេដ្ឋកិច្ចដ៏សំខាន់របស់ប្រជាជនកម្ពុជា។ ទន្លេមេគង្គ និងដៃរបស់វាដោយរួមផ្សំនឹងទឹកភ្លៀង ដែលហូរធ្លាក់ចូលមកពីតំបន់នានា បានធ្វើអោយមានទឹកជំនន់ ប្រចាំឆ្នាំ ក្នុងនោះផ្ទៃដីប្រមាណជា ១៧.១០០គម[២] (ស្មើនឹង២៥%) នៃតំបន់វាលទំនាប អាងទន្លេមេគង្គ។ ខ្យល់ព្យុះបាននាំមកនូវការធ្លាក់ភ្លៀងខ្លាំង និងដោយសារមានការកាប់ព្រៃឈើដ៏ច្រើនផងនោះ បានធ្វើឱ្យកើតមានទឹកជំនន់រហ័ស (ទឹកជំនន់ទឹកភ្លៀង) ។

នៅក្នុងប្រទេសកម្ពុជា ទន្លេមេគង្គតែងតែហូរហៀរចាក់ពាសពេញលើមាត់អាងទន្លេ ដែលធ្វើអោយមានទឹកជំនន់នៅតាមខេត្ត ដែលមានទីតាំងនៅតាមបណ្តោយតំបន់ទំនាបទន្លេមេគង្គ ។ តំបន់លិចទឹកនៅជុំវិញក្រុងភ្នំពេញ និងតាមតំបន់មួយ

ចំនួនទៀតរហូតដល់ ព្រំដែនប្រទេសវៀតណាមមានផ្ទៃក្រលាប្រមាណជា ៧.០០០គម$^{២}$ តំបន់ទាំងនេះ តែងតែទទួលរងការប៉ះពាល់ជាប្រចាំ ដូចជា ខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តកណ្តាល និងខេត្តព្រៃវែង និង ខេត្តស្វាយរៀង ។

តាមរបាយការណ៍របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ថាទឹកជំនន់ឆ្នាំ ២០០០ ជាទឹកជំនន់ធំ និង ធ្ងន់ធ្ងរជាងគេក្នុងរយៈពេល ៧០ឆ្នាំ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) បានរាយការណ៍ថា មានមនុស្សស្លាប់ ចំនួន ៣៤៧នាក់ ដែលក្នុងនោះ ៨០ % ជាកុមារ ហើយគ្រួសារចំនួន ៧៥០.៦១៨គ្រួសារ នៅក្នុងខេត្ត-ក្រុងចំនួន២១ ទទួលរងផលប៉ះពាល់ដោយសារទឹកជំនន់ដែលក្នុងនោះមានប្រជាជនចំនួន៨៥.០០០ គ្រួសារបានជំលៀសបណ្តោះអាសន្នទៅកាន់ទីទួលសុវត្ថិភាព។ ផ្ទះចំនួន ៣១៧.៩៧៥ ខ្ទងបានទទួលរងការប៉ះពាល់ និង ចំនួន ៧.០៦៨ ខ្ទង ត្រូវបំផ្លិចបំផ្លាញទាំងស្រុង។ យោងតាមរបាយការណ៍របស់ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(NCDM), រាជរដ្ឋាភិបាលកម្ពុជា បានប៉ាន់ប្រមាណតំលៃនៃការខូចខាត និងប៉ះពាល់ដោយសារទឹកជំនន់ឆ្នាំ ២០០០ នេះ សរុបអស់ប្រហែលជា ១៥៧ លានដុល្លារ ។ ទឹកជំនន់ឆ្នាំបន្ទាប់ ២០០១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) បានធ្វើការប៉ាន់តំលៃការខូចខាត និងប៉ះពាល់អស់ប្រហែល ៣៦ លានដុល្លារ ហើយនៅក្នុងឆ្នាំ ២០០២ មនុស្សចំនួនប្រហែលជា ១.៥ លាននាក់ និង ផ្ទៃដីកសិកម្ម ប្រហែលជា ៦០.០០០ហិចតា ត្រូវទទួលរងការផលប៉ះពាល់ដោយគ្រោះទឹកជំនន់នេះ ។

ទឹកជំនន់តែងតែបង្កនូវការខូចខាត និងបាត់បង់ ។ ទន្ទឹមនឹងនេះ ទឹកជំនន់ក៏តែងតែផ្តល់ផលប្រយោជន៏ដល់ប្រជាជនផងដែរ ។ ទឹកជំនន់ទន្លេមេគង្គបានផ្តល់ត្រីយ៉ាងសំបូរបែប និងសំបូរជីវចំរុះគ្រប់ប្រភេទនៅក្នុងតំបន់, ផ្តល់ទឹកប្រើប្រាស់, ជាផ្លូវនាវាចរណ៍, ផ្តល់ដី ល្បាប់ដ៏មានជីជាតិសំរាប់ដីកសិកម្ម ។ តំបន់ដីសើមនៅតាមទំនាបទន្លេមេគង្គ ជាប្រភពធនធានដ៏សំខាន់សំរាប់ផ្តល់នូវជីវភាពរស់នៅ របស់ប្រជាជនរាប់លាននាក់ ដោយបានផ្តល់ស្បៀងអាហារ និង ផលិតផលតំបន់ដីសើម ។

## វិធីសាស្ត្រនៃការគ្រប់គ្រងគ្រោះទឹកជំនន់ថ្នាក់តំបន់

នៅក្នុងកិច្ចខិតខំប្រឹងប្រែងដោះស្រាយសេចក្តីត្រូវការសំរាប់វិធានការការពារគ្រោះទឹកជំនន់ទន្លេមេគង្គ ទើបគណៈកម្មការទន្លេមេគង្គ បានបង្កើតយុទ្ធសាស្ត្រថ្នាក់តំបន់ថ្មីមួយ ក្នុងគោលបំណងដើម្បីពង្រឹង "ការត្រៀមបង្ការ និង ការកាត់បន្ថយគ្រោះទឹកជំនន់ទន្លេមេគង្គ និង ដើម្បីយកផលប្រយោជន៏ពីទឹកជំនន់" ។ ដូចបានគូសបញ្ជាក់ខាងលើ អាងទន្លេមេគង្គបានទទួលរងការប៉ះពាល់ដោយទឹកជំនន់ដ៏ធំ និងធ្ងន់ ក្នុងរយៈពេល ៧០ឆ្នាំ នៅក្នុងឆ្នាំ ២០០០ ។ ជាការឆ្លើយតបទៅនឹងគ្រោះមហន្តរាយធម្មជាតិបែបនេះ លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គបានសំរេចបង្កើតកម្មវិធីគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ (FMMP) ។ កម្មវិធីនេះ ដើម្បីធានាថា ប្រជាជនដែលរស់នៅក្នុងតំបន់ប្រឈមមុខនឹងទឹកជំនន់នៅក្នុងប្រទេសជាសមាជិកទាំងបួន មាន កម្ពុជា, ឡាវ, ថៃ, និង វៀតណាម ( មិនថាប្រទេសណាដែលរងគ្រោះជាងគេនោះទេ) មានការត្រៀមបង្ការយ៉ាងល្អទៅនឹងទឹកជំនន់នៅពេលអនាគត ។ យុទ្ធសាស្ត្រនេះ គេទទួលស្គាល់ថាមានតែមួយគត់ សំរាប់គ្រប់គ្រងទឹកជំនន់នៅថ្នាក់ជាតិ តំបន់ និងឆ្លងព្រំដែន ដែលផ្អែកលើទំហំនៃការរងនូវផលប៉ះពាល់របស់វា។ ដូច្នេះកម្មវិធីនេះត្រូវបាន ចាត់ទុកថាជាកម្មវិធីឆ្លងប្រទេស ។



*ផ្នែកទាំង៥ របស់កម្មវិធីគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់*

តាមការពិត មានតំរូវការជាច្រើនទាក់ទងនឹងទឹកជំនន់ក្នុងចំណោមប្រទេសជាសមាជិក គណៈកម្មការទន្លេមេគង្គ ទាំងតំរូវការមូលដ្ឋាន តំរូវការថ្នាក់តំបន់ និង តំរូវការឆ្លងដែន ដែលប្រទេសនីមួយៗបានចង្អុលបង្ហាញនូវអាទិភាពរបស់ខ្លួន ដល់គណៈកម្មការទន្លេមេគង្គ ដើម្បីអោយគណៈកម្មាការនេះ អាចកំនត់បាននូវតួនាទី របស់ខ្លួនសំរាប់កម្មវិធីថ្មីនេះ។ ផ្អែកតាមតំរូវការ និងអាទិភាពរួម របស់ប្រទេសជាសមាជិកនីមួយៗ ទើបផ្នែកទាំង៥ សំរាប់ប្រតិបត្តិការទាក់ទងនឹងទឹកជំនន់ បានបង្កើតឡើងក្នុងកម្មវិធីគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់នេះ ។

ដូចនេះយុទ្ធសាស្ត្រថ្នាក់តំបន់មួយបានរៀបចំឡើង ។ ការបង្កើតយុទ្ធសាស្ត្រនេះក្នុងគោលបំណងការពារ កាត់បន្ថយ ទុក្ខវេទនារបស់ប្រជាជន និង ការខូចខាតសេដ្ឋកិច្ចដោយសារគ្រោះទឹកជំនន់ ។គោលបំណងនៃកម្មវិធីនេះដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះទឹកជំនន់ និង ថែរក្សាបរិស្ថានអោយនៅគង់វង្សពិសេសលើកតំកើងជីវភាពប្រជាជនដែលរស់នៅតាមតំបន់អាងទន្លេមេគង្គនេះ ។

## ផ្នែកទី៤ នៃកម្មវិធីគ្រប់គ្រង និង កាត់បន្ថយគ្រោះទឹកជំនន់ : ពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់

ការអនុវត្តន៏ផ្នែកទី៤ នៃកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ "ពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់" នេះកំពុងតែអនុវត្តដោយគណៈកម្មការទន្លេមេគង្គ(MRC) ដោយមានការគាំទ្រ បច្ចេកទេសពីមជ្ឈមណ្ឌលត្រៀមបង្កាគ្រោះមហន្តរាយអាស៊ី(ADPC) ហើយទទួលជំនួយមូលនិធិពីភ្នាក់ងារសហប្រតិបត្តិការជំនួយបច្ចេកទេសអន្តរជាតិ ប្រទេសអាឡឺម៉ង់ (GTZ) ។

គោលបំណងនៃគំរោងនេះ គឺដើម្បីធានាថា "ប្រព័ន្ធគ្រប់គ្រង គ្រោះអាសន្ននៅក្នុងប្រទេសតាមដងទន្លេមេគង្គមានប្រសិទ្ធភាពទប់ទល់នឹងទឹកជំនន់ទន្លេមេគង្គ" ។ លទ្ធផលទាំងអស់របស់គំរោង នេះគឺ " ដើម្បីលើកកំពស់សមត្ថភាពអាជ្ញាធរស៊ីវិលគ្រប់លំដាប់ថ្នាក់, អ្នកគ្រប់គ្រងគ្រោះអាសន្ន និង សហគមន៏ទាំងឡាយ នៅក្នុងការត្រៀមបង្ការ និងកាត់បន្ថយគ្រោះទឹកជំនន់" ។




គំរោងនេះចាប់ផ្តើមអនុវត្តនៅក្នុងខែកញ្ញា ឆ្នាំ២០០៤ ហើយបញ្ចប់នៅក្នុងខែធ្នូ ឆ្នាំ២០០៧។ គំរោងនេះត្រូវបានអនុវត្តនៅក្នុងខេត្តពីរដែលងាយរងគ្រោះដោយទឹកជំនន់បំផុតនៅក្នុងប្រទេសកម្ពុជា: ខេត្តកណ្តាល និងព្រៃវែង។ ស្រុកចំនួនពីរនៅក្នុងខេត្តនីមួយៗត្រូវបានជ្រើសរើសសំរាប់ការអនុវត្តសាកល្បង: ស្រុកពាមជរ៍ និងស៊ីធរកណ្តាល នៃខេត្តព្រៃវែង និង ស្រុកលើកដែក និងល្វាឯម នៃខេត្តកណ្តាល។ ស្រុកទាំងបួនមានទីតាំងនៅក្នុងតំបន់ទឹកជំនន់ទន្លេមេគង្គហើយនិងស្ថិតនៅក្នុងចំណោមស្រុកដែលងាយរងគ្រោះបំផុតដោយសារទឹកជំនន់នៅក្នុងខេត្តនីមួយៗ។

### ស្ថាប័នជាតិ និងស្ថាប័នក្រោមបង្គាប់, យន្តការ និងសមត្ថភាព ដើម្បីគ្រប់គ្រងគ្រោះមហន្តរាយ

នៅក្នុងឆ្នាំ១៩៩៥ ដែលជាលទ្ធផលនៃបទពិសោធន៍ជាមួយនឹង គ្រោះមហន្តរាយដែលកើតឡើងជាប្រចាំសំរាប់ប្រទេស រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈរដ្ឋមន្ត្រី។ គណៈកម្មាធិការនេះមានប្រធានគ្រប់គ្រងដោយនាយករដ្ឋមន្ត្រី និងបណ្តាក្រសួងពាក់ព័ន្ធជាសមាជិក។ ថ្នាក់ក្រោមរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដូចជា គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត, ស្រុក និង ឃុំ ត្រូវបានបង្កើតឡើងដោយមានមន្ទីរពាក់ព័ន្ធរបស់គេជាសមាជិក។

## កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ : ការកសាងសមត្ថភាពនៅថ្នាក់ខេត្ត និង ស្រុក

លទ្ធផលមួយក្នុងចំណោមលទ្ធផលសំខាន់ទាំងឡាយរបស់គំរោងនេះគឺការរៀបចំ និងបង្កើតកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់នៅថ្នាក់ ខេត្ត និងស្រុក។ កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់នេះត្រូវបានគេ កំណត់ជាជំហាន៧ជាមុនទៅក្នុងផែនការហើយចាត់ជាវិធានការណ៍ អនុវត្តជាអាទិភាពមុនពេលទឹកជំនន់មកដល់ដើម្បីធានាថាសកម្មភាពការពារត្រូវបានគេរៀបចំអោយបានត្រឹមត្រូវនិងមានប្រសិទ្ធិភាព ក្នុងពេល និងបន្ទាប់ពីទឹកជំនន់។

មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយបានសំរបសំរួលក្នុងដំណើរការរៀបចំកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់នេះ ដោយផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ជាពិសេសផ្តល់វគ្គបណ្តុះបណ្តាលដល់អជ្ញាធរខេត្ត និងស្រុក ហើយនិងគាំទ្រទៅលើការអនុវត្តវិធានការណ៍កាត់បន្ថយគ្រោះភ័យ នៃគ្រោះទឹកជំនន់។

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងស្រុក បានផ្តល់នូវការសំរបសំរួលយ៉ាងសំខាន់ដោយមានការចូលរួមពីគ្រប់មន្ទីរ/ការិយាល័យ និងអ្នកដែលពាក់ព័ន្ធផ្សេងៗនៅថ្នាក់ខេត្តនិងស្រុក។ជនបង្គោលនៅក្នុងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តនិងស្រុកបានក្លាយទៅជាផ្នែកមួយដ៏សំខាន់នៅក្នុងរៀបចំបង្កើតនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ហើយបន្ទាប់មកដើរតួនាទីជាអ្នកសំរបសំរួលសំរាប់សកម្មភាពបង្កើនសមត្ថភាពទាំងឡាយ។

### ការវិភាគលើតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័ន

នៅពេលចាប់ផ្តើមគំរោងដំបូង មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី រួមជាមួយនឹងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានធ្វើការសិក្សាទៅលើ "ការវិភាគលើតួនាទីស្ថាប័ន និង កំនត់សេចក្តីត្រូវការសំរាប់ពង្រឹង"។ អ្នកចូលរួមក្នុងការសិក្សានេះ គឺជាសមាជិករបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ដែលជាអ្នកពាក់ព័ន្ធក្នុងការធ្វើផែនការ និងអនុវត្តនូវរាល់បញ្ហាទាក់ទង នឹងទឹកជំនន់។

ការសិក្សានេះបានធ្វើឡើងនៅខេត្តកណ្តាល និង ខេត្ត ព្រៃវែង កាលពីឆ្នាំ ២០០៥។ គោលបំណង នៃការសិក្សានេះ ដើម្បីស្វែងយល់អោយបានស៊ីជំរៅលើប្រព័ន្ធគ្រប់គ្រងគ្រោះទឹកជំនន់ដែលមានស្រាប់ ដើម្បីផ្តល់ការគាំទ្រដល់អាជ្ញាធរថ្នាក់ខេត្តនិងស្រុក។ដោយធ្វើការពិនិត្យមើលលើតួនាទីនិងការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និង ស្រុក (PCDM/DCDM)។លទ្ធផលការសិក្សានេះ បានជួយអោយដឹងពីឧបសគ្គនៅក្នុងប្រព័ន្ធគ្រប់គ្រងគ្រោះទឹកជំនន់ និងតើត្រូវចាប់ផ្តើមពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ដែលធ្វើអោយគេអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពខ្ពស់។

តួនាទីកាលពីមុន របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត (PCDM) និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក(DCDM) គឺគ្រាន់តែផ្តល់ពត៌មានដល់សហគមន៍ និងរាយការណ៍ជូនរាជរដ្ឋាភិបាល និងអង្គការអ្នកផ្តល់ជំនួយ ដើម្បីទទួលបានជំនួយសង្គ្រោះជូនប្រជាជនរងគ្រោះតែប៉ុណ្ណោះ។

នៅពេលដែលទឹកជំនន់កើតឡើង តួនាទីសំខាន់របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តគឺសំរបសំរួលការទំនាក់ទំនងផ្ទាល់ជាមួយបណ្តាមន្ទីរពាក់ព័ន្ធ និងអង្គភាពសហប្រតិបត្តិការផ្សេងៗ ព្រមទាំងផ្តល់ពត៌មានដល់រាជរដ្ឋាភិបាលនូវហេតុការណ៏នោះ។ នៅថ្នាក់ជាតិវិញ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ធ្វើការជាមួយបណ្តាក្រសួងពាក់ព័ន្ធនានា និង អង្គការក្រៅរដ្ឋាភិបាល ដើម្បីធ្វើការឆ្លើយតប និង ផ្តល់ជំនួយដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និង ស្រុក (PCDM/DCDM)។



ទាក់ទងនឹងប្រព័ន្ធរាយការណ៏ពតិមានវិញបានបង្ហាញអោយឃើញថាប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងប្រទេសកម្ពុជាមិនត្រឹមតែរង់ចាំការណែនាំ និងពឹងផ្អែកលើធនធានរបស់រដ្ឋាភិបាលប៉ុណ្ណោះទេ តែជំនួយសង្គ្រោះបន្ទាន់សំរាប់ឆ្លើយតបនឹងភាពអាសន្ន ក៏មានកំរិតដែរ។ ដោយសារខ្វះខាតនូវជំនួយគាំទ្រ និងការយល់ដឹងអំពីតួនាទី ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយរបស់បណ្តាក្រសួងពាក់ព័ន្ធនៅមានកំរិតដែរ។ រចនាសម្ព័ន្ធដែលមានស្រាប់ នៅមានចំនុចខ្សោយ ផ្អែកប្រព័ន្ធទំនាក់ទំនង ដោយសារខ្វះការសហការគ្នា ។

ទោះបីជាការសំរបសំរួលរវាងបណ្តាមន្ទីរ-អង្គភាពពាក់ព័ន្ធ ដែលជាសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និង ស្រុក (PCDM/DCDM) ក៏ដោយក៏ប្រព័ន្ធគ្រប់គ្រងនេះនៅមានភាពទន់ខ្សោយ និងមានកំរិត ។ លោក លឹម គឹមនី ជាមន្ត្រីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តកណ្តាលបានគូសបញ្ជាក់ថាមានសកម្មភាពជាច្រើនដែលអនុវត្តជាន់គ្នាដោយសារតែខ្វះការចែក រំលែកពតិមាន និង សហការគ្នា។ លើសពីនេះទៀត កង្វះខាតទិន្នន័យពតិមានពីគ្រោះទឹកជំនន់ និង ខ្វះផែនទីបង្ហាញតំបន់លិចទឹកជាកត្តាធ្វើអោយខ្វះខាតការទទួលពតិមានពីគ្រោះទឹកជំនន់ផងដែរ។

ជាចុងក្រោយនេះ ប្រការសំខាន់បំផុតនោះគឺគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយមានការខ្វះខាតធនធានសំខាន់ៗជាច្រើន ដូចជាមធ្យោបាយដឹកជញ្ជូនឧបករណ៏សំភារៈ ហិរញ្ញវត្ថុ និង ធនធានមនុស្សដែលមានជំនាញ។

## ដំណើរការរៀបចំសៀវភៅណែនាំស្តីពីកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់

ការរៀបចំ "*សៀវភៅណែនាំស្តីពីការត្រៀមបង្ការគ្រោះទឹកជំនន់ សំរាប់អជ្ញាធរថ្នាក់ខេត្តនិងស្រុកនៃប្រទេសស្ថិតនៅតាមដងទន្លេមេគង្គក្រោម*" មានគោលបំណងពីរ គឺជួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៃប្រទេសតាមដងទន្លេក្នុងការរៀបចំនិងអនុវត្តកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់របស់ពួកគេនិងជួយអជ្ញាធរគ្រប់គ្រង គ្រោះមហន្តរាយជាតិ និងមូលដ្ឋានក្នុងសកម្មភាពបង្កើនសមត្ថភាពដល់មន្ត្រីគ្រប់គ្រងគ្រោះមហន្តរាយរបស់គេ អ្នកអនុវត្ត និងអង្គការក្រៅរដ្ឋាភិបាលនានា។



សៀវភៅណែនាំនេះផ្តោតទៅលើដំណើរការរៀបចំផែនការត្រៀមបង្ការគ្រោះទឹកជំនន់ និងជំហានក្នុងការអនុវត្តរបស់កម្មវិធី ត្រៀមបង្ការគ្រោះទឹកជំនន់ដោយមានដោយមានឧទាហរណ៏ពីវិធានការណ៏ត្រៀមបង្ការកាត់បន្ថយ និងការឆ្លើយតប។ ឧទាហរណ៏ និងបទពិសោធន៏មេរៀនដែលទទួលបានពីការអនុវត្តន៏កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់នៅថ្នាក់ខេត្ត និងស្រុកត្រូវបានដាក់បញ្ចូលទៅក្នុងឯកសារនេះផងដែរ។

សៀវភៅណែនាំនេះបានរៀបចំដោយប្រើប្រាស់ជាប្រធានបទបញ្ហានៅក្នុងសកម្មភាពបណ្តុះបណ្តាលពីមុន ហើយនិងព័តិមានដែលប្រមូលបាននៅក្នុងដំណើរការរៀបចំកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់នៅថ្នាក់ខេត្ត និងស្រុកនៅក្នុងប្រទេសកម្ពុជា និងឡាវ។ សៀវភៅនេះរួមមាន ១០ជំពូកដែលផ្តល់នូវការយល់ដឹងជាមូលដ្ឋាន និងរៀបរាប់ពីដំណើរការរៀបចំអនុវត្តសំរាប់ផែនការត្រៀមបង្ការគ្រោះទឹកជំនន់។ សៀវភៅនេះត្រូវបានគេប្រើប្រាស់ដោយបណ្តាលអង្គភាពជាតិ និងគណៈកម្មាធិការខេត្តនានានៅក្នុងសកម្មភាពបណ្តុះបណ្តាល និងក្នុងកម្មវិធីត្រៀមបង្ការ និងកាត់បន្ថយគ្រោះទឹកជំនន់របស់ពួកគេ។

សៀវភៅណែនាំនេះជាភាសាអង់គ្លេសត្រូវបានបែងចែកយ៉ាងទូលំទូលាយនៅសិក្ខាសាលាថ្នាក់តំបន់ដែលប្រារព្ធធ្វើឡើងនៅខេត្ត ខុនកែន (Khon Kaen) ប្រទេសថៃ ក្នុងខែតុលា ឆ្នាំ២០០៧។ សៀវភៅណែនាំនេះបានបកប្រែជាភាសាខ្មែរ ហើយត្រូវបានបែងចែកនៅក្នុងសិក្ខាសាលាចែករំលែកបទពិសោធន៏ថ្នាក់ជាតិដែលបានរៀបចំនៅក្នុងខេត្តព្រៃវែង ខែវិច្ឆិកា ឆ្នាំ ២០០៧។




*រចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ, កម្ពុជា*

## ការចូលរួមក្នុងដំណើរការរៀបចំកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ និងការអនុវត្ត

កាលពីខែមិថុនា ឆ្នាំ២០០៥ សិក្ខាសាលាពិគ្រោះយោបល់ចំនួន២ បានរៀបចំឡើងនៅខេត្តកណ្តាល និងខេត្តព្រៃវែង ។នៅក្នុងសិក្ខាសាលាទាំង២នេះ សមាជិករបស់គណៈកម្មាធិការនេះ បានបង្ហាញលទ្ធផលនៃការសិក្សាវិភាគតួនាទីស្ថាប័ន និងអនុសាសន៏ដើម្បីពង្រឹង។ សិក្ខាសាលាបានឯកភាពតំរូវអោយមានការរៀបចំកម្មវិធី ច្បាស់លាស់មួយនៅថ្នាក់ខេត្ត ដែលកម្មវិធីនេះបានកំនត់អោយបានច្បាស់លាស់នូវតួនាទីនិងការទទួលខុសត្រូវរបស់មន្ទីរអង្គភាពដែលជាសមាជិកគណៈកម្មាធិការ ក្នុងដំណាក់កាលមុនពេល កំឡុងពេល និង ក្រោយពេលទឹកជំនន់។ ក្រោយពីសិក្ខាសាលាមក កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់បានរៀបចំដោយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តនិងស្រុកដោយមានការជួយផ្តល់បច្ចេកទេសពីក្រុមពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)។

យោងទៅលើកិច្ចសិក្សាកាលពីឆ្នាំ២០០៥បានរកឃើញនូវភាពខ្វះចន្លោះជាច្រើនក្នុងប្រព័ន្ធត្រៀមបង្ការគ្រោះទឹកជំនន់ដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា ដូចជា កង្វះខាតនៃដំណើរការធ្វើ ផែនការដោយមានការចូលរួមជាប្រព័ន្ធលើវិធានការត្រៀមបង្ការត្រៀមបង្ការគ្រោះទឹកជំនន់នៅថ្នាក់ខេត្ត និងស្រុក នេះជាឧបសគ្គសំខាន់របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងស្រុក (PCDM/DCDM)។ ការគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងប្រទេសកម្ពុជា បានផ្តោតសំខាន់តែលើការឆ្លើយតប និងផ្តល់ជំនួយសង្គ្រោះ នៅពេលដែលទឹកជំនន់បានកើតឡើងរួចហើយប៉ុណ្ណោះ តែមិនបានយកចិត្តទុកដាក់ខ្លាំងក្នុងការអនុវត្តវិធានការការពារ និងត្រៀមបង្ការ ជាមុនប៉ុន្មានទេ។

បន្ទាប់ពីមានការប្រជុំ ការពិគ្រោះយោបល់ និងសិក្ខាសាលាផែនការជាបន្តបន្ទាប់រួចមក កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ថ្នាក់ខេត្ត និងស្រុកទាំងអស់ត្រូវបានរៀបចំបង្ហើយនៅក្នុងខែកុម្ភៈ ឆ្នាំ២០០៦។ នេះតំណាងអោយប្រវត្តិមួយនៃការត្រៀមបង្ការគ្រោះទឹកជំនន់ និងការគ្រប់គ្រងគ្រោះអាសន្ននៅក្នុងខេត្ត និងស្រុកគោលដៅទាំងអស់ ដែលពួកគេជាចុងក្រោយបានបង្កើតអោយមានកម្ម

វិធីត្រៀមបង្ការគ្រោះទឹកជំនន់នេះឡើងសំរាប់លើកដំបូង។

វិធីសាស្រ្តចូលរួមក្នុងការរៀបចំបង្កើតកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ទាំងនេះគឺការកសាងសមត្ថភាពរបស់ក្រុមគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត និង ស្រុក និងធ្វើអោយគេសំរេចបាននូវជោគជ័យដ៏ធំរបស់ពួកគេ ។

" កាលពីអតីតកាល យើងបង្កើតគណៈកម្មាធិការបណ្តោះអាសន្ន ដែលមានតំណាងមកពីនាយកដ្ឋានពាក់ព័ន្ធ។ គណៈកម្មាធិការនឹង ជួយនៅពេលមានគ្រោះមហន្តរាយ "

វេជ្ជ. សុទ្ធ គីមកុលមុន្នី
ជំនួយការអគ្គលេខាធិការរង
គ.ជ.គ.ម



*សិក្ខាសាលាពិគ្រោះយោបល់ ត្រូវបានសំរបសំរួលយល់ព្រមពីសិក្ខាកាម ដែលផែនការត្រៀមបង្ការគ្រោះទឹកជំនន់ថ្នាក់ខេត្តត្រូវតែបង្កើតឡើង។*

## នៅក្នុងដំណើរការកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់

កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់និមួយៗមានពតិមានទាក់ទងនឹងខេត្តឬស្រុកនិមួយៗ សកម្មភាពដែលមានស្រាប់ (នីតិវិធីប្រតិបត្តិការ) របស់បណ្តាមន្ទីរ-អង្គភាពពាក់ព័ន្ធ នៅមុនពេល កំឡុងពេល និងក្រោយពេលគ្រោះទឹកជំនន់ លក្ខខ័ណ្ឌការងាររបស់ក្រុម ប្រតិបត្តិទាំងបួន ដែលមានដូចជា ក្រុមរុករកសង្គ្រោះ និង សន្តិសុខ, ក្រុមសុខភាព អនាម័យ និង ទឹកស្អាត ក្រុមគ្រប់គ្រងពតិមាន និងផ្សព្វផ្សាយអប់រំ និងក្រុមប្រតិបត្តិការឆ្លើយតប និងសង្គ្រោះបន្ទាន់ និងបញ្ជីសកម្មភាពជាអាទិភាពក្នុងការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ ដែលក្រុមនិមួយៗត្រូវធ្វើការទាក់ទងនឹងក្រុម ឬ អង្គភាពពាក់ព័ន្ធជាក់លាក់នៅក្នុងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ។

*លោក លឹម គីមនី ជាសិក្ខាកាមរបស់សិក្ខាសាលា បានមានប្រសាសន៍ថា គំនិតផ្តួចផ្តើមកិច្ចសហប្រតិបត្តិការនេះ គឺជាសកម្មភាពមួយសំរាប់"ការជួយអោយពួកយើងយល់នូវអ្វី (មន្ទីរនីមួយៗ) ដែលយើងបានធ្វើជាក់ស្តែង*

## អត្ថប្រយោជន៍នៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់

ជោគជ័យសំខាន់នៅក្នុងការរៀបចំ និង អនុវត្តកម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយគឺបានពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងស្រុកដោយបានអនុវត្តវិធីសាស្រ្ត ធ្វើអោយមានកិច្ចសហការ។ ដោយបានធ្វើការកំនត់តួនាទី និងការទទួលខុសត្រូវរបស់បណ្តាមន្ទីរ-អង្គភាពច្បាស់លាស់ទាំងនេះនិងក្លាយជាវិភាគទានដ៏មានទំនុកចិត្តមួយក្នុងការគ្រប់គ្រងគ្រោះទឹកជំនន់។ លើសពីនេះទៀត ការកសាងសមត្ថភាពនៅថ្នាក់សហគមន៍ប្រជាជនមានអារម្មណ៏កក់ក្តៅក្នុងការគ្រប់គ្រងគ្រោះទឹកជំនន់នៅ ពេលអនាគតដោយខ្លួនគេ។

ឯកឧត្តម ប៉ុន ណារិទ្ធ បានគូស បញ្ជាក់ថា"កាលពីមុន ប្រជាជននៅក្នុងសហគមន៏ ខ្វះការយល់ដឹងពីវិធីគ្រប់គ្រងគ្រោះមហន្តរាយ។ វិធីសាស្រ្តដែលមានការចូលរួមបានជួយពង្រឹងកិច្ចសហប្រតិបត្តិការនៅគ្រប់លំដាប់ថ្នាក់តាំងពីថ្នាក់លើរហូតដល់ថ្នាក់មូលដ្ឋាន។ ការកំនត់នូវតួនាទី និង ការទទួលខុសត្រូវរបស់មន្ទីរ-អង្គភាពច្បាស់លាស់ វាបានធ្វើអោយមន្ទីរអង្គភាពនានាមានការយល់គ្នា និងបានបង្កើនប្រសិទ្ធិភាព ក្នុងការចែករំលែកពតិមានគ្នាទៅវិញទៅមក។ ជាពិសេស វាអាចជួយបញ្ចៀសបាននូវការយល់ច្រឡំគ្នាក្នុងការអនុវត្តការងារ ។ ឯកឧត្តមបានបន្ថែមទៀតថាវាក៏ជាឱកាសល្អក្នុងការស្វែងរក និងប្រមូលធនធាននៅគ្រប់ថ្នាក់ដែរ។

ដោយសារដំណើរការនៃការរៀបចំកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់នេះធ្វើអោយមន្ទីរ-អង្គភាពនានាបានទទួលស្គាល់តំរូវការអោយ មានកម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយជាអចិន្ត្រៃយ៏។



*ឯ.ឧ ប៉ុន ណារិទ្ធអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយកម្ពុជា បានមានប្រសាសន៏ថា" កាលពីមុន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត (PCDM) ទទួលពតិមានព្យាករណ៏ទឹកជំនន់ តាមរយៈនាយកដ្ឋានជលសាស្រ្ត និងការងារទន្លេ (DHRW)ហើយផ្តល់ពតិមាននេះទៅអោយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក (DCDM) ហើយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក (DCDM)ផ្តល់ពតិមានដល់អ្នកភូមិពីស្ថានភាពទឹកជំនន់ដែលកំពុងឡើងនឹងមានរៀបចំកិច្ចប្រជុំ នៅតាមបណ្តាស្រុក ដោយមានការចូលរួមពីតំណាងឃុំ" ។*

បន្ទាប់ពីពេលមានគ្រោះមហន្តរាយហើយ គណៈកម្មាធិការនេះ នឹងលែងមាន ដូច្នេះគណៈកម្មាធិការនេះផ្តោតសំខាន់តែទៅលើ ការងារឆ្លើយតបសង្គ្រោះបន្ទាន់តែមិនបានផ្តោតសំខាន់ទៅលើការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ។ "ប៉ុន្តែឥឡូវនេះ វាគ្មានករណីនេះទៀតទេ។ ពួកគេយល់ថាវាគឺជាការទទួលអំណោយ និង ជំនួយសង្គ្រោះ ដូចជា ស្បៀង និង សំភារៈផ្សេងៗតែប៉ុណ្ណោះ។ ក្រោយពីមានផែនការត្រៀមបង្ការគ្រោះទឹកជំនន់នេះមកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ស្រុក និង សហគមន៏ ទទួលបានចំណេះដឹងពីរបៀបរៀបចំផែនការនិងរបៀបត្រៀមបង្ការទឹកជំនន់នៅដំណាក់មុនពេល អំឡុងពេល និង ក្រោយពេលទឹកជំនន់ "។



លោក ឌី ពិសិដ្ឋ អនុប្រធានការិយាល័យកសិកម្មស្រុកពាមជរ៍បានមានប្រសាសន៍ថា "យើងបានទទួលចំណេះដឹងពីរបៀបបង្កើតតារាងផលប៉ះពាល់ដែលយើងអាចបំពេញពតិមានដោយផ្ទាល់ ដូចជាចំនួនសាលារៀន ទីទួលសុវត្ថិភាព ចំនួនគ្រួសារ...បន្ទាប់ពីវគ្គបណ្តុះបណ្តាលនេះ ហើយយើងបានយល់ពីការងារដែលមានលក្ខណ:ជាប្រព័ន្ធជាងមុន"។

## សមិទ្ធិផលសំរេចបាន

គំរោងពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់បានរៀបចំកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ ហើយជាស្ថាពរបានចំនួន ៦ គឺ ថ្នាក់ខេត្តចំនួន ២ នៅក្នុងខេត្តកណ្តាល និង ព្រៃវែង និង ថ្នាក់ស្រុកចំនួន ៤ គឺ នៅក្នុងស្រុកល្វាឯម លើកដែក ពាមជរ៍ និង ស្រុកស៊ីធរកណ្តាល ។

ផ្អែកតាម កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ទាំងនេះសកម្មភាព អាទិភាពមួយចំនួនធំត្រូវបានកំនត់ និងបានអនុវត្ត។ សកម្មភាពអាទិភាពទាំងនោះរួមមាន : ការរៀបចំប្រព័ន្ធផ្តល់ពតិមានជាមុននៅ ស្រុកពាមជរ៍ និង ស្រុកស៊ីធរកណ្តាលការបើកវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងគ្រោះទឹកជំនន់នៅមូលដ្ឋានសហគមន៍ (CBFM) វគ្គបណ្តុះបណ្តាលស្តីពីការវាយតំលៃការខូចខាត និង តំរូវការ (DANA) សកម្មភាពបង្កើនការយល់ដឹងជាសាធារណៈការរៀបចំកម្មវិធីស្តីពីការកំនត់រកនូវតំរូវការរបស់ស្ត្រីជាមេគ្រួសារ (WHHs) ការកំនត់ធនធាន និងការកែលំអលើទីទួលសុវត្ថិភាពជាដើម។

បទពិសោធន៏ទទួលបាន និង ការអនុវត្តន៏ល្អនានា នៃការរៀបចំ និងការអនុវត្តកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ ត្រូវបានកំពុងពង្រីកទៅដល់តំបន់នានាទៀត ដែលជាតំបន់ស្ថិតនៅក្រៅស្រុក និងខេត្តគោលដៅ នៅពេលបច្ចុប្បន្ននេះ ដូចជា ក្រចេះ ខេត្តកំពង់ចាម ខេត្តតាកែវ ខេត្តស្វាយរៀង ស្រុកពាមរក៏(ខេត្តព្រៃវែង) និង ស្រុកកៀនស្វាយ(ខេត្តកណ្តាល) ។

### យន្តការធានានិរន្តរភាពរយៈពេលយូរអង្វែង

ដោយមានកិច្ចសហការជាមួយនឹងក្រសួងផែនការកម្មវិធីគាំទ្រកិច្ចអភិវឌ្ឍន៏បែបប្រជាធិបតេយ្យតាមរយ: វិមជ្ឈការ និងវិសហមជ្ឈការ (PSDD) (ពីមុនជាកម្មវិធីសិលា) បាននឹងកំពុងអនុវត្តផែនការអភិវឌ្ឍន៏ឃុំ-សង្កាត់(CDP) និងកម្មវិធីវិនិយោគ ឃុំ-សង្កាត់(CIP) ។ផែនការអភិវឌ្ឍន៏ឃុំ-សង្កាត់ ជាផែនការដែល ឃុំ-សង្កាត់ រៀបចំដោយខ្លួនឯង ។

ផែនការនេះ ផ្តោតសំខាន់លើការអភិវឌ្ឍន៏ដើម្បីដោះស្រាយ បញ្ហា និងសេចក្តីត្រូវការទាក់ទង នឹងវិស័យនានាដូចជា សេដ្ឋកិច្ច សង្គមកិច្ច ធនធាន និង បរិស្ថានធម្មជាតិ រដ្ឋបាល និង សន្តិសុខ និង យេនឌ័រ ។ គោលបំណងនៃផែនការនេះ គឺដើម្បីកំនត់សេចក្តីត្រូវការ គោលដៅ និង យុទ្ធសាស្ត្រ និង ថវិកា សំរាប់អនុវត្តតាមសេចក្តីត្រូវការរបស់ឃុំ-សង្កាត់។ កាលពីខែវិច្ឆិកា ឆ្នាំ២០០៦គំនិតផ្តួចផ្តើមនៅក្នុងការដាក់បញ្ចូលវិធានការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ (ទឹកជំនន់) ត្រូវបានចាប់ផ្តើម។ ការធ្វើសមាហរណកម្ម "កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ទៅក្នុងផែនការអភិវឌ្ឍន៏ឃុំ-សង្កាត់ (CDP) ជាចំណុចសំខាន់ក្នុងការធានានូវការអភិវឌ្ឍន៏មូលដ្ឋាន ប្រកបដោយនិរន្តរភាព ។

ចាប់ពីខែកញ្ញា ឆ្នាំ២០០៧កម្មវិធីគាំទ្រកិច្ចអភិវឌ្ឍន៏បែបប្រជាធិបតេយ្យតាមរយ:វិមជ្ឈការ និងវិសហមជ្ឈការ (PSDD) បានចាប់ផ្តើមសំរបសំរួលឃុំ-សង្កាត់ក្នុងការរៀបចំផែនការអភិវឌ្ឍន៏ឃុំ (CDP)។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានសហការជាមួយកម្មវិធីគាំទ្រកិច្ចអភិវឌ្ឍន៏បែបប្រជាធិបតេយ្យ តាមរយ: វិមជ្ឈការ និង វិសហមជ្ឈការ (PSDD) និងដោយមានជំនួយបច្ចេកទេសពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC) បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយសំរាប់មន្ត្រីអ្នកសំរបសំរួលថ្នាក់ខេត្ត និង ស្រុក ដែលជាមន្ត្រីរបស់កម្មវិធីគាំទ្រកិច្ចអភិវឌ្ឍន៏បែបប្រជាធិបតេយ្យតាមរយ:វិមជ្ឈការ និង វិសហមជ្ឈការ PSDD ដើម្បីធានាអោយមានការដាក់បញ្ចូលវិធានការកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៏ឃុំ-សង្កាត់ CDP ។

## មេរៀនទទួលបាន និង ផលវិបាកនៅពេលអនាគត

**មានបទពិសោធន៏ទទួលបានជាច្រើនពីការរៀបចំនិងអនុវត្តកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ :**

- ការវិភាគស្ថាប័នបានជួយយើងជាច្រើននៅក្នុងការកំនត់តួនាទីនិងការទទួលខុសត្រូវរបស់មន្ទីរ-អង្គភាពនីមួយៗ ដែលជាសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងស្រុក។
- ការធ្វើផែនការរួមគ្នាអាចពង្រឹងបាននូវការចែករំលែកពតិមានការយល់ដឹង និងសហការគ្នាបានល្អរវាងមន្ទីរ-អង្គភាពនៅ ថ្នាក់ខេត្ត ស្រុក ឃុំ និងជាតិ ។
- ការដឹកនាំរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងស្រុកក្នុងការរៀបចំផែនការ បានបង្ហាញអោយឃើញថា គេមានសមត្ថភាពគ្រប់គ្រាន់។
- ការធ្វើផែនការ និងការអនុវត្តផែនការ ធ្វើអោយមន្ទីរ-អង្គភាពទទួលស្គាល់នូវតួនាទី និងការទទួលខុសត្រូវរបស់គេ ក្នុងការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ និងគេអាចស្វែងរកធនធានពីខាងក្នុងដើម្បីគាំទ្របានទៀតផង ។
- ការចូលរួមផ្តល់ជំនួយបច្ចេកទេសពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយជាផលប្រយោជន៏សំខាន់ ដើម្បីជួយធានាបាននូវនិរន្តរភាព។

**ផលវិបាកដែលប្រឈមមុខនឹងការបន្តអនុវត្តកម្មវិធីមានដូចតទៅ :**

- ការធ្វើអោយមានទំនាក់ទំនងនៅក្នុងដំណើរការរៀបចំកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់នៅគ្រប់ថ្នាក់។
- ការបញ្ជ្រាបកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ទៅក្នុងដំណើរការផែនការអភិវឌ្ឍន៏ ជាពិសេស ដំណើការអភិវឌ្ឍន៏ ឃុំ សង្កាត់ ដែលកំពុងអនុវត្តក្រោមកម្មវិធីគាំទ្រកិច្ចអភិវឌ្ឍន៏បែបប្រជាធិបតេយ្យតាមរយ:វិមជ្ឈការ និង វិសហមជ្ឈការ (PSDD)
- ការធ្វើអោយមាននិរន្តរភាពនៃដំណើរការរៀបចំកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ ជាពិសេសនៅតាមបណ្តាឆ្នាំដែលមានគ្រោះទឹកជំនន់ ។
- ការលៃលកធនធានសំរាប់គាំទ្រការអនុវត្តកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់
- ការបន្តពង្រីកដំណើរការរៀបចំកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ទៅបណ្តាខេត្តនិងស្រុកដទៃទៀត។
- ការបញ្ចូលបញ្ហាយេនឌ័រទៅក្នុងកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់។

## ទំរង់កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ថ្នាក់ខេត្ត នៅក្នុងប្រទេសកម្ពុជា


**អារម្ភកថា**
**ក្រុមការងារ**
**១_សេចក្តីផ្តើម**
១.១-ប្រវត្តិ
១.២-គ្រោះទឹកជំនន់ និង ផលប៉ះពាល់(២០០០ ២០០១ ២០០២ ២០០៣)
១.៣-គោលដៅ និង យុទ្ធសាស្ត្រក្នុងការធ្វើផែនការ
ក-ហេតុអ្វីបានជាធ្វើផែនការ
ខ-តើផែនការត្រៀមបង្ការគ្រោះទឹកជំនន់នេះអាចជួយ យើងបានអ្វីខ្លះ?
គ-អ្នកណាធ្វើផែនការ
ឃ-តើផែនការនេះកើតឡើងយ៉ាងដូចម្តេច?
ង-តើផែនការនេះសំរាប់អ្នកណា?
១.៤-ការទទួលខុសត្រូវ និង សិទ្ធិអំណាច
១.៥-កាលបរិច្ឆេទនៃការរៀបចំ និង កែសំរួលផែនការ
**២_ប្រវត្តិរបស់ខេត្ត**
២.១-ទីតាំងភូមិសាស្ត្រ និង ទំហំផ្ទៃដី
ក-ពតិមានលំអិតពីទីតាំងរបស់ខេត្ត
ខ-ចំនួនស្រុក ឃុំ និង ភូមិ
គ-ផ្ទៃដី និង ប្រភេទដី
ឃ-សាលារៀន
ង-មណ្ឌលសុខភាព និង មន្ទីរពេទ្យ
២.២-ប្រជាសាស្ត្រ
ក-មុខរបរសំខាន់ៗរបស់ប្រជាជន
ខ-សកម្មភាពចំណូល
គ-ពតិមានលំអិតពីប្រជាជនតាមស្រុក
ឃ-កិរិតវប្បធមិ
២.៣-ទន្លេសំខាន់ ៗ និង ធនធានទឹក
ក-ទន្លេសំខាន់ៗ
ខ-ប្រភពទឹកផ្សេងទៀត
គ-ប្រព័ន្ធធារាសាស្ត្រ
**៣_ការវិភាគមុខសញ្ញាបង្កគ្រោះមហន្តរាយ ភាពងាយរងគ្រោះនិងសមត្ថភាព**
៣.១-ការវិភាគមុខសញ្ញាបង្កគ្រោះមហន្តរាយ
៣.២-ការវិភាគភាពងាយរងគ្រោះ
៣.៣-ការវិភាគធនធាន
ក-ទីទួលសុវត្ថិភាព និង ទីតាំង
ខ-មធ្យោបាយដឹកជញ្ជូន
គ-ធនធានមនុស្ស
ឃ-អង្គការនានា
**៤_យន្តការស្ថាប័ន និង ការគ្រប់គ្រង**
៤.១-គណ:កម្មាធិការខេត្តគ្រប់គ្រងគ្រោះមហន្តរាយ
ក-សមាសភាព
ខ-តួនាទីនិងការទទួលខុសត្រូវរបស់គណ:កម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត
គ-រចនាសម្ព័ន្ធគណ:កម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត
៤.២-ក្រុមគ្រប់គ្រងគ្រោះមហន្តរាយខេត្ត
៤.៣-និតិវិធីប្រតិបត្តិការស្តង់ដារសំរាប់វិធីធានការត្រៀមបង្ការប្រតិបត្តិការ ឆ្លើយតប និង ស្តារឡើងវិញ
**៥_ការត្រៀមបង្ការគ្រោះទឹកជំនន់**
៥.១-ការពង្រឹងសមត្ថភាព និងបណ្តុះបណ្តាល
៥.២-ការងារផ្សព្វផ្សាយ និង បង្កើនការយល់ដឹង
៥.៣-ប្រព័ន្ធផ្តល់ពតិមានជាមុនពីគ្រោះទឹកជំនន់ និងឧបករណ៏វាស់ ស្ទង់ទឹក
៥.៤-ការស្តុក និង ការគ្រប់គ្រងឃ្លាំងស្តុកសំភារ: និងជំនួយសង្គ្រោះ
៥.៥-យុទ្ធសាស្ត្រ សង្គ្រោះ ជំលៀស និង ស្រាវជ្រាវរកជនរងគ្រោះ
៥.៦-ការរៀបចំ និង គ្រប់គ្រងទីទួលសុវត្ថិភាពមុនពេលមានគ្រោះ ទឹកជំនន់
៥.៧-ការរៀបចំ និង ការគ្រប់គ្រងប្រព័ន្ធពតិមាន
**៦_ប្រតិបត្តិការឆ្លើយតបសង្គ្រោះបន្ទាន់**
៦.១-ត្រួតពិនិត្យមុខសញ្ញាបង្កគ្រោះមហន្តរាយ និង គ្រោះថ្នាក់ដែលអាចកើតឡើង
៦.២-ការព្យាករណ៏ និង ការផ្តល់ពតិមានជាមុនពីគ្រោះមហន្តរាយ ទឹកជំនន់
៦.៣-យុទ្ធសាស្ត្រសង្គ្រោះ ជំលៀស និងស្រាវជ្រាវរុករកជនរងគ្រោះនៅរដូវ ទឹកជំនន់
៦.៤-ការគ្រប់គ្រងប្រជាជនដែលជំលៀសមកស្នាក់នៅលើទីទួល សុវត្ថិភាពនៅរដូវទឹកជំនន់
៦.៥-កម្មវិធីផ្នែកសុខភាព អនាម័យ និងទឹកស្អាត
៦.៦-ការវាយតំលៃ និងការប៉ាន់ប្រមាណផលប៉ះពាល់និង សេចក្តីត្រូវការរបស់ជនរងគ្រោះ
៦.៧-ប្រតិបត្តិការឆ្លើយតបជំនួយសង្គ្រោះបន្ទាន់
**៧_ការស្តារ និង ជួសជុលឡើងវិញ**
៧.១-ការវាយតំលៃ និង ការប៉ាន់ប្រមាណការខូចខាត និងសេចក្តីត្រូវការដើម្បីស្តារ និងជួសជុលឡើងវិញ
៧.២-ការរៀបចំផែនការ និង យុទ្ធសាស្ត្រស្តារ និងជួសជុលឡើងវិញ
៧.៣-អនុវត្តផែនការ និងយុទ្ធសាស្ត្រស្តារ និងជួសជុលឡើងវិញ ក្រោយពីគ្រោះមហន្តរាយ
**៨_វិធានការកាត់បន្ថយគ្រោះថ្នាក់ដែលអាចកើតឡើង (មុនទឹក ជំនន់)**
**ក_វិធានការកាត់បន្ថយបែបរូបវន្ត (ទំនប់ ប្រឡាយ ទីទួល សុវត្ថិភាព ។ល។)**
៨.១-បង្កើតគណ:កម្មាធិការប្រតិបត្តិ និង ថែរក្សាគំរោងនៅថ្នាក់ ស្រុក និង ឃុំ
៨.២-កំនត់និងវាយតំលៃមុខសញ្ញាបង្កគ្រោះមហន្តរាយ ភាពងាយរងគ្រោះ និង សមត្ថភាពរបស់សហគមន៏
៨.៣-រៀបចំផែនការសំរាប់អនុវត្តគំរោងកាត់បន្ថយគ្រោះថ្នាក់ ដែលអាចកើតឡើង
៨.៤-អនុវត្តផែនការសកម្មភាព
**ខ_វិធានការកាត់បន្ថយគ្រោះភ័យបែបមិនមែនរូបវន្ត(គោលនយោបាយអភិវឌ្ឍន៏ ការប្រមូលធនធាន និងមូលនិធិ)**
៨.៥-ស្វែងរកធនធាន និង ការគាំទ្របច្ចេកទេសពីមន្ទីរអង្គភាព និងរដ្ឋាភិបាល ដើម្បីគាំទ្រផែនការ
៨.៦-ស្វែងរកធនធាន និង ការគាំទ្របច្ចេកទេសពីអង្គការនៅក្នុង ខេត្ត និងអង្គការអ្នកផ្តល់ជំនួយនានា ដើម្បីគាំទ្រការផែនការ
៨.៧-រៀបចំ និងបង្កើតគោលនយោបាយសំរាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយគ្រប់ថ្នាក់
**៩_ឯកសារភ្ជាប់**
ក-ឯកសារអំពីធានធានដែលមានស្រាប់ (ធនធានមនុស្ស និង ធនធានផ្សេងៗ)
ខ-ស្ថាប័ន ឬ អង្គសំរាប់ទំនាក់ទំនង
គ-ផែនទីខេត្ត



### សេចក្តីថ្លែងអំណរគុណ

សហគមន៏មានសុវត្ថិភាព សូមថ្លែងអំណរគុណចំពោះការចូលរួមចំណែកពីអ្នកទាំងអស់ដូចខាងក្រោមក្នុងការរៀបចំចងក្រងករណីសិក្សានេះ :

លោក Aloysisus Rego ប្រធានក្រុម ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ, ប្រទេសថៃ
លោក Thanongdeth Insisiengmay ប្រធានគ្រប់គ្រងកម្មវិធី ពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ ADPC, ប្រទេសកម្ពុជា
លោក Aslam Perwaiz ប្រធានគ្រប់គ្រងគំរោង, ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ, ប្រទេសថៃ
លោក ជុំ វុទ្ធី , ប្រធានគ្រប់គ្រងគំរោងថ្នាក់ជាតិ, ADPC, ប្រទេសកម្ពុជា
លោក អុល សែន, អ្នកសំរបសំរួលកម្មវិធី, ADPC, ប្រទេសកម្ពុជា
លោក ប៊ី ច័ន្ទតុលា, ជំនួយការគំរោង, ADPC, ប្រទេសកម្ពុជា
អ្នកស្រី Xanthe Cobb, អ្នកនិពន្ធ
លោក លឹម តារា, អ្នករចនាអត្ថបទ

សហគមន៍មានសុវត្ថិភាព ជាឈុតនៃករណីសិក្សា ដែលបានដកស្រង់យកអនុវត្តន៍ល្អៗមកបង្ហាញទាក់ទងនឹងការត្រៀមបង្ការ និងកាត់បន្ថយ គ្រោះមហន្តរាយ ដែលបានអនុវត្តដោយរាជរដ្ឋាភិបាលនិង អង្គការក្រៅរដ្ឋាភិបាល សំដៅកាត់បន្ថយភាពងាយរងគ្រោះ និង គ្រោះភ័យនៃគ្រោះមហន្តរាយរបស់សហគមន៍ ដែលរស់នៅក្នុងតំបន់ប្រឈមមុខនឹងមុខសញ្ញាបង្កគ្រោះមហន្តរាយនានា ។

ករណីសិក្សានេះ មានទិសដៅផ្តល់ដល់អ្នកធ្វើការសំរេចចិត្ត អ្នកធ្វើផែនការអភិវឌ្ឍន៍ អ្នកអនុវត្តន៍ការងារគ្រប់គ្រងគ្រោះមហន្តរាយ អ្នកដឹកនាំសហគមន៍ និង អ្នកអប់រំនានានូវគំនិតច្នៃប្រឌិត ឧបករណ៍ យុទ្ធសាស្រ្ត និង ជំរើសគោលនយោបាយនានា ដែលបានដកស្រង់ពីបទពិសោធន៍ពិតប្រាកដ ការអនុវត្តន៍ល្អៗ និង មេរៀនល្អៗ ដែលទទួលបានពីតំបន់អាស៊ីប៉ាស៊ីហ្វិច ទាក់ទង នឹងការកាត់បន្ថយគ្រោះភ័យនៃគ្រោះ មហន្តរាយ និង កាត់បន្ថយភាពងាយរងគ្រោះរបស់សហគមន៍ ព្រមទាំងកសាងអោយបាននូវភាពជួយខ្លួនឯងរបស់សហគមន៍ និង ធ្វើអោយមានសង្គម ដែលមានការត្រៀមបង្ការគ្រោះមហន្តរាយបានល្អប្រសើរ ។

ក្នុងដំណាក់កាលទី១នេះ ករណីសិក្សាមួយចំនួនត្រូវបានរៀបចំក្រោមផ្នែកទី៤ "គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS)" នៃកម្មវិធីគ្រប់គ្រង និង កាត់បន្ថយ គ្រោះទឹកជំនន់ (FMMP) របស់គណៈកម្មការទន្លេមេគង្គ ។ ដូចនេះករណីសិក្សានេះបានផ្តោតសំខាន់តែទៅលើការគ្រប់គ្រងគ្រោះភ័យនៃគ្រោះទឹកជំនន់នៅតាមតំបន់ភូមិសាស្រ្តនៃប្រទេស ជាសមាជិកគណៈកម្មការទន្លេមេគង្គ ដែលមាន ប្រទេស កម្ពុជា ឡាវ ថៃឡង់ដ៏និងវៀតណាម ។ទោះបីជាយ៉ាងណាក៏ដោយ បទពិសោធន៍និង ការអនុវត្តន៍ល្អៗដែលទទួលបាន ពីបណ្តាប្រទេសដទៃទាក់ទងនឹងគ្រោះ មហន្តរាយធម្មជាតិនឹងត្រូវដាក់បញ្ចូលបន្ថែម នៅពេលក្រោយៗទៀត ។

គោលបំណងនៃកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ របស់គណៈកម្មាធិការទន្លេមេគង្គ គឺដើម្បីការពារ និងកាត់បន្ថយទុក្ខវេទនារបស់ប្រជាជន និងការខូចខាតសេដ្ឋកិច្ច ដែលបណ្តាលមកពី គ្រោះទឹកជំនន់ និងថែរក្សាបរិស្ថាននៃទឹកជំនន់អោយនៅគង់វង្ស ។ កម្មវិធីគ្រប់គ្រង និង កាត់បន្ថយគ្រោះទឹកជំនន់មាន ៥ផ្នែកសំខាន់ៗដូចខាងក្រោម:

ផ្នែកទី ១ : បង្កើតមជ្ឈមណ្ឌលគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់

ផ្នែកទី ២ : វិធានការណ៏បែបរចនាសម្ព័ន្ធ និងការទប់ស្កាត់គ្រោះទឹកជំនន់

ផ្នែកទី ៣ : ការសំរបសំរួលបញ្ហាគ្រោះទឹកជំនន់ឆ្លងដែន

ផ្នែកទី ៤ : ការពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់

ផ្នែកទី ៥ : ការគ្រប់គ្រងដី

ផ្នែកទី៤ "គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS)" នៃកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ (FMMP) នេះ ត្រូវបានអនុវត្តដោយគណៈកម្មការទន្លេមេគង្គ ដោយជំនួយបច្ចេកទេស ពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី និងឧបត្ថម្ភថវិកាដោយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ប្រទេសអាឡឺម៉ង់ (GTZ) ដែលបានចាប់ផ្តើមពីខែកញ្ញា ឆ្នាំ២០០៤ ដល់ខែមេសា ឆ្នាំ២០០៨។ តំបន់គោលដៅរបស់គំរោងនេះមាននៅក្នុងប្រទេសកម្ពុជា និងវៀតណាម ដែលប្រទេសនីមួយៗយកខេត្ត២ និងស្រុក៤ ជាតំបន់គោលដៅ ។ ដៃគូររបស់គំរោងនេះ មានគណៈកម្មាធិការជាតិទន្លេមេគង្គ, គណៈ កម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអាជ្ញាធរមូលដ្ឋានប្រចាំខេត្ត ស្រុក និងឃុំរបស់គេ, មន្ទីរ-ការិយាល័យពាក់ព័ន្ធ, ស្ថាប័នផ្សេងៗ, កាកបាទក្រហម, អង្គការអន្តរជាតិ, អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ, ។ល ។

ចាប់តាំងពីឆ្នាំ ២០០៤ មក គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS) បានសំរេចសមិទ្ធិផលដូចខាងក្រោម:

១-កម្មវិធិត្រៀមបង្ការគ្រោះទឹកជំនន់ នៅក្នុងស្រុកនិងខេត្តគោលដៅត្រូវបានបង្កើត និងអនុវត្ត

២-សមត្ថភាពថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិត្រូវបានបង្កើនក្នុងការគាំទ្រទៅលើដំណើរការបង្កើត និងអនុវត្តកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ តាមរយៈការបណ្តុះបណ្តាលនៅកំរិតមូលដ្ឋាន ស្តីការគ្រប់គ្រង គ្រោះទឹកជំនន់នៅតាមសហគមន៏, ការប៉ាន់ប្រមាណការខូចខាតនិងសេចក្តីត្រូវការ, ការរុករកនិងសង្គ្រោះ, ការគ្រប់គ្រងគ្រោះអាសន្នដល់កុមារតូចៗ, ការបង្ហាត់ហែលទឹកដល់កុមារ ។ល ។ ហើយនិងការចូលរួម ទៅក្នុងការអនុវត្តគំរោង ។

៣-ការផ្សព្វផ្សាយយល់ដឹងជាសាធារណៈស្តីពីវិធានការសុវត្ថិភាពគ្រួសារថ្នាក់មូលដ្ឋានត្រូវបានបង្ហាញ រួមមានការផ្សព្វផ្សាយដល់គ្រូបង្រៀន និងកម្មវិធីសុវត្ថិភាពគ្រោះទឹកជំនន់នៅតាមសាលារៀន, ការកំណត់ពីតំរូវការចាំបាច់របស់ស្រ្តីមេគ្រួសារ, ការសំដែងសិល្បៈ, ចាប៉ីដងវែង, ការចែកផ្សព្វផ្សាយសៀវភៅទឹកជំនន់, ផ្ទាំងរូបភាព ជាដើម ។

៤-ការចែករំលែកបទពិសោធន៏ថ្នាក់មូលដ្ឋាន និងតំបន់ត្រូវបានរៀបចំឡើងតាមរយៈសិក្ខាសាលាជាតិ និងតំបន់ ព្រមទាំងធ្វើការបែងចែកឯកសារបទពិសោធន៍ល្អៗជាច្រើន ។

---

**សំរាប់ពត៌មានបន្ថែម អ្នកអានអាចទាក់ទងអាស័យដ្ឋានដូចខាងក្រោម**


អ្នកសំរបសំរួលកម្មវិធីគ្រប់ គ្រងនិងកាតបន្ថយគ្រោះទឹកជំនន់
មជ្ឈមណ្ឌលគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់,
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អាគារលេខ ៥៧៦, ផ្លូវជាតិលេខ២, សង្កាត់ចាក់អង្រែក្រោម, ខ័ណ្ឌមានជ័យ, រាជធានីភ្នំពេញ
គេហទំព័រ : www.mrcmekong.org

ប្រធានគ្រប់គ្រងកម្មវិធី, មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី
មជ្ឈមណ្ឌលគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់,
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អាគារលេខ ៥៧៦, ផ្លូវជាតិលេខ២, សង្កាត់ចាក់អង្រែក្រោម, ខ័ណ្ឌមានជ័យ, រាជធានីភ្នំពេញ
គេហទំព័រ : www.adpc.net email : antonio@adpc.net


---

**ដៃគូរគំរោង**


លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRC)
ប្រអប់សំបុត្រលេខ ៦១០១ អគារលេខ ១៨ បានស៊ីថានេនូវ ខ័ណ្ឌស៊ីកុតថាបុង
ក្រុងវៀងច័ន្ទ ប្រទេសឡាវ
ទូរស័ព្ទ: (៨៥៦) ២១ ២៦៣ ២៦៣ ទូរសារ: (៨៥៦) ២១ ២៦៣ ២៦៤
អ៊ីម៉ែល: mrcs@mrcmekong.org វ៉ិបសាយ: http://www.mrcmekong.org

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (CNMC)
ផ្ទះលេខ ២៣ មហាវិថីម៉ៅសេទុង ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ: (៨៥៥) (២៣) ២១៨ ៧២៧ ទូរសារ: (៨៥៥) (២៣) ២១៨ ៥០៦
អ៊ីម៉ែល: cnmcs@cnmc.gov.kh វ៉ិបសាយ: http://www.camnet.com.kh/cnmcs

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)
ផ្លូវលេខ ៥១៦ សង្កាត់ទួលសង្កែ ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ/ ទូរសារ: (៨៥៥) (២៣) ៨៨២ ០៤៥

លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តកណ្តាល (PCDM)
ឃុំដើមមាន ស្រុកតាខ្មៅ ខេត្តកណ្តាល ប្រទេសកម្ពុជា
ទូរសារ: (៨៥៥) (២៣) ៤២៥៥៥៥

លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង (PCDM)
ឃុំកំពង់លាវ ស្រុកកំពង់លាវ ខេត្តព្រៃវែង ប្រទេសកម្ពុជា
ទូរសារ: (៨៥៥) (២៣) ៩៤៤ ៥៤៦

មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC)
SM Tower, ជាន់ ទី២៤, ៩៧៩/៦៩, Paholyothin, Samsen Nai, Phayathai,
ក្រុងបាងកក, ប្រទេសថៃ
ទូរស័ព្ទ: (៦៦) ២២ ៩៨ ០៦៨១ ដល់ ៩២
ទូរសារ: (៦៦) ២២ ៩៨ ០០១២ ដល់ ១៣
អ៊ីម៉ែល: adpc@adpc.net វ៉ិបសាយ: www.adpc.net

ឧបត្ថម្ភដោយ:

gtz Partner for the Future Worldwide
on behalf of:
Federal Ministry for Economic Cooperation and Development

ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស ប្រទេសអាឡឺម៉ង់ (GTZ)